ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១២៦

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤

សាលដីកា

លេខ : ២២

ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៥

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ស៊ិន ឌីម | ចៅក្រម |
| ៤- លោក | វៀល មួន | ចៅក្រម |
| ៥- លោក | ប្រាក់ គីមសាន | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោក សាន សុផាត

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២៨"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១២៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

***ចំពោះ*** : ធ្វើអោយខូចខាតដោយចេតនា ទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិគោកត្នោត ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

-ជនជាប់ចោទឈ្មោះសរ សារ៉េត (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចំបក់បែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប របររកស៊ីធ្វើទាហាន ទីលំនៅសព្វថ្ងៃភូមិមណ្ឌល I ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះបួង ហាស់ "រ" ម្តាយឈ្មោះនេង សារ៉ាត់ "រ" ប្រពន្ធឈ្មោះកែវ គីមលី មានកូន០៣នាក់ ។ ក្រៅឃុំ ។ មានមេធាវី លោក លួង សុខា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលីវ ម៉ូវ(ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិក្រសួងមហាផ្ទៃ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩៧ ផ្លូវលេខ២១៤ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយមេធាវី លោកស្រី ពីង ធីតា ។

-តាមរបាយការណ៍សំយោគលេខ១១៩៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ថា : កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ ឧត្តមសេនីយត្រី លីវ ម៉ូវ បានប្តឹងរាយការណ៍ស្តីពីករណីមានជនល្មើសទៅគាស់កកាយកាប់កាត់យកដែកបំផ្លាញពុម្ពរបងផ្ទះរបស់ខ្លួន កាលពីម៉ោង១០នៅភូមិសាស្ត្រ ភូមិជ្រៃ ឃុំសណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ ឆ្លងតាមការស៊ើបអង្កេតរបាយការណ៍បានសន្និដ្ឋាន និង វាយតំលៃថា : ករណីកើតមានខាងលើពិតជារឿងព្រហ្មទណ្ឌប្រាកដមែន ។ រាល់អំពើទាំងអស់ពិតជាបង្កឡើងដោយឈ្មោះពេជ្រ កេតសាណា និង សរ សារ៉េត យោធាខេត្តសៀមរាប និង កម្មករមួយចំនួនទៀត ជាអ្នកធ្វើដោយផ្ទាល់ប្រាកដមែន ។

- បានឃើញដីកាសំរេចលេខ៣៧៧ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ របស់ព្រះរាជអាជ្ញា អមតុលាការខេត្តសៀមរាប ដែលបានសំរេច :

+ ដាក់សំណុំរឿងព្រហ្មទណ្ឌលេខ១១៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៤ ដែលមានម្ចាស់បណ្តឹងឈ្មោះលីវ ម៉ូវ និង កម្មវត្ថុបណ្តឹងធ្វើឱ្យខូចខាតដោយចេតនានូវទ្រព្យសម្បត្តិអ្នកដទៃ ជារឿងបញ្ហាបន្ទាន់បង្វែរកតាមមាត្រា២៥-២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះខេង ស៊ុំ តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលីវ ម៉ូវ ប្តឹងមិនសុខចិត្តនឹងដីកាសំរេចលេខ៣៧៧ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ របស់ព្រះរាជអាជ្ញា អមតុលាការខេត្តសៀមរាប លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា: គប្បីបដិសេធចោលដីកាសំរេចដាក់រឿងជាបញ្ហាបន្ទាន់បង្វែរ របស់តំណាងអយ្យការ អមតុលាការខេត្តសៀមរាបចោលជាអសារបង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៨"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះខេង ស៊ុំ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈដីកាសំរេចលេខ៣៣៧ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៤ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តសៀមរាប ពេញទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៤៨ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ទៅព្រះរាជអាជ្ញា អមតុលាការខេត្តសៀមរាប ដើម្បីចាត់ការជារឿងព្រហ្មទណ្ឌបន្តដល់អង្គសេចក្តីដោយចោទប្រកាន់ជនជាប់ចោទសង្ស័យ ពីបទ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ តាមការយល់ឃើញខាងលើ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខជនជាប់ចោទឈ្មោះសរ សារ៉េត ,ចាន់ វ៉ាន់នី និង ស៊ិន លី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១២៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះសរ សារ៉េត និង ស៊ិន លី ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ២៨"ឈ"ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍

លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះសរ សារ៉េត (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់លោកលីវ ម៉ូវ (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : តុលាការខេត្តសៀមរាបបានសំរេចដាក់រឿងនេះ ជារឿងបញ្ហាបន្ទាន់បង្ហំ ជាការមិនត្រឹមត្រូវទេ មហាអយ្យការ អមតុលាការកំពូល និង មហាអយ្យការ អមសាលាឧទ្ធរណ៍ យល់ថា រឿងនេះពុំមែនបញ្ហាបន្ទាន់បង្ហំទេ ព្រោះមានភស្តុតាងច្បាស់លាស់ឈ្មោះលីវ ម៉ូវ មានប្លង់កម្មសិទ្ធិហើយ ។ ដូច្នេះអំពើរបស់ជនជាប់ចោទ គឺជាអំពើល្មើសនឹងច្បាប់ព្រហ្មទណ្ឌ សូមតុលាការសំរេចចុះ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណារបស់ឈ្មោះសរ សារ៉េត (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាតប របស់ឈ្មោះលីវ ម៉ូវ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកល្វង សុខា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះសរ សារ៉េត (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ឈ្មោះលីវ ម៉ូវ ធ្វើប្លង់កម្មសិទ្ធិលើដីកូនក្តីខ្ញុំ ដែលមានប្លង់កម្មសិទ្ធិហើយព្រោះដីនេះទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងការពារជាតិ បានប្រគល់មកឱ្យកូនក្តីខ្ញុំ ទើបកូនក្តីខ្ញុំរុះរើរបងនេះចេញ ។ រឿងនេះមានភាពស្រពិចស្រពិលរកម្ចាស់កម្មសិទ្ធិជាមុខសិន ទើបសំរេចរឿងព្រហ្មទណ្ឌជាក្រោយ ។ ខ្ញុំបាទសំណូមពរសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រីពីង ធីតា ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលីវ ម៉ូវ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះ ថា : កូនក្តីនាងខ្ញុំបានទិញដីនេះមានម្ចាស់កម្មសិទ្ធិត្រឹមត្រូវមានកំណត់ហេតុវាស់វែងទទួលស្គាល់ព្រំប្រទល់ពីអ្នកជិតខាង ហើយឈ្មោះសរ សារ៉េត និង បក្សពួកបានមកកាត់ដែកចេញ ជាអំពើល្មើសព្រហ្មទណ្ឌ ព្រោះមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីនេះកូនក្តីនាងខ្ញុំមានប្លង់កម្មសិទ្ធិរួចហើយ សូមតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលសវនាការថា : គ្មានអ្វីបន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីនៃជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះសរ សារ៉េត និង ស៊ិន លី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការលើកឡើងរបស់ឈ្មោះសរ សារ៉េត ក្នុងសារណាចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៥ ថា ដីផ្លូវទំនាស់ជាដីរបស់យោធាដែលធ្វើកើតចេញជាផ្លូវ និង កំពុងប្រើប្រាស់ជាសធារណៈក្នុងពេលបច្ចុប្បន្ននោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ពុំមានភស្តុតាងណាបញ្ជាក់ថា ដីទំនាស់ជាផ្លូវកំពុងប្រើប្រាស់ជាសាធារណៈ ឬស្ថិតក្នុងគំរោងដើម្បីបើកជាផ្លូវសាធារណៈឡើយ ។

+មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីទំនាស់កំពុងស្ថិតនៅក្នុងការកាន់កាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញដោយអគ្គនាយកសុរិយោដី និង ភូមិសាស្ត្រតាំងពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០០ ម្ល៉េះ ។

+ការដែលជនជាប់ចោទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដែលពុំមែនជារបស់ខ្លួន ទោះក្នុងករណីណាក៏ដោយ ក៏ត្រូវចាត់ទុកជាអំពើល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសតាមច្បាប់ ។

-យល់ឃើញថា ទាំងជនជាប់ចោទ ទាំងដើមបណ្តឹងរដ្ឋប្បវេណីពុំបានមកចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីបានមកចូលរួមសវនាការនេះហើយ ។ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងថា រឿងនេះជារឿងបន្ទាន់បង្ខំ ពីព្រោះប័ណ្ណសំគាល់សិទ្ធិរបស់លោកលីវ ម៉ូវ ស្ថិតក្នុងភាពស្រពិចស្រពិលនៅឡើយ ។ប៉ុន្តែការដែលកូនក្តីលោក គឺជនជាប់ចោទទៅកាត់បំផ្លាញខ្សែលួសរបស់គេ ដោយឯកឯងនោះ ជាបទល្មើសព្រហ្មទណ្ឌហើយ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ២៨"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

*វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី*

*ប៉ុន្តែចាត់ទុកជាចំពោះមុខ :*

១-ទទួលបណ្តឹងសាទុក្ខលេខ១២៣ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះសរ សារ៉េត និង ឈ្មោះស៊ិន លី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៨"ឈ" ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១២៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅតុលាការខេត្តសៀមរាបចាត់ការបន្តតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៥ ។